ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១០២ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**ប្រការ ១.**_

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **វង សូត** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ២- លោកជំទាវ | **ខៀវ បូរី** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម | **គុល ជីវរក្ស** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- លោកជំទាវ | **កែម ចរិយា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |

CS Scanned with CamScanner

៥- លោកជំទាវ **ឆេព ម៉ូរ៉ាមីន** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន

៦- ឯកឧត្តម **គុប សុផ័ក** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

៧- ឯកឧត្តម **ឆុយ វី** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៨- លោកជំទាវ **គ្រុយ លាងស៊ីម** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិកា

៩- ឯកឧត្តម **ថោង ម៉ូរ៉ាន់** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១០- លោកជំទាវ **រ៉ៅញ៉ែម មរកត** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិកា

១១- ឯកឧត្តម **គាម ម៉ារិទ្ធីយ៉ា** អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

១២- ឯកឧត្តម **គុយ ឆាយ** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១៣- ឯកឧត្តម **ចាប ឫទ្ធី** អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៤- ឯកឧត្តម **សុខ សុយ៉ុន** អនុរដ្ឋលេខាធិការក្រសួងផែនការ សមាជិក

១៥- ឯកឧត្តម **ថោង សុគន្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការសង្គម នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៦- លោកជំទាវ **ពុំ ចន្ទីនី** អគ្គលេខាធិការកាកបាទក្រហមកម្ពុជា សមាជិកា

១៧- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក។

**ប្រការ ២._**

សេចក្តីសម្រេចលេខ៩៥ ស.សរ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាព គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២ កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner